**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**

**សំណុំរឿងព្រហ្មទណ្ឌលេខ ១០៤០**

**ចុះថ្ងៃទី ០៦-វិច្ឆិកា-២០២២**

**សាលក្រមព្រហ្មទណ្ឌ**

**លេខ: ២៥០/២៩ ក្រ១ "ខ"**

**ចុះថ្ងៃទី ០៤-តុលា-២០២៣**

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តព្រះសីហនុ**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក និងប្រកាសសាលក្រម នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ ដោយមានសមាសភាព:

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ជាប្រធានក្រុមប្រឹក្សា

-ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា

-លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

**ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១០៤០ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២ ដែលមាន:**

**-ជនជាប់ចោទ:**

១-ឈ្មោះ [redacted] **មេត្តា** ភេទប្រុស កើតឆ្នាំ១៩៩៩ (អាយុ២៣ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីកន្លែងកំណើតនៅ [redacted] ខេត្តពោធិ៍សាត់ មុខរបរ មិនពិតប្រាកដ មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិ៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] **ស្រីល័ក្ខ** មានកូនចំនួន០២នាក់ ឪពុកឈ្មោះ [redacted] **ខុម** "ស្លាប់" ម្តាយឈ្មោះ [redacted] **ខឿន** "ស្លាប់" ជានីតិជន ទោសពីមុនគ្មាន។

**(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៥៤២ ដ.ប.ឃ.ខ/ច/២២ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តព្រះសីហនុ)**

២-ឈ្មោះ [redacted] **ចិន** ភេទប្រុស កើតឆ្នាំ២០០០ (អាយុ២២ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីកន្លែងកំណើតនៅ [redacted] ខេត្តពោធិ៍សាត់ មុខរបរ កម្មករសំណង់ មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] **ស្រីល័ក្ខ** មានកូនចំនួន ០២នាក់ ឪពុកឈ្មោះ [redacted] **ខុម** "ស្លាប់" ម្តាយឈ្មោះ [redacted] **ខឿន** "ស្លាប់" ជានីតិជន ទោសពីមុនគ្មាន។

**(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៥៤៣ ដ.ប.ឃ.ខ/ច/២២ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តព្រះសីហនុ)**

ជាប់ចោទពីបទ **អំពើលួចមានស្ថានទម្ងន់ទោស** និងបទ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្ត នៅចំណុចក្រុមហ៊ុនផ្លូវល្បឿនលឿន ស្ថិតក្នុងភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៧, មាត្រា ៤១០ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិ។



Scanned with CamScanner

-ជនរងគ្រោះ

ឈ្មោះ [redacted] វ៉ុក ភេទប្រុស កើតថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៨២ (អាយុ៤០ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។

## អង្គហេតុនៃបណ្ដឹងចោទប្រកាន់

កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង ២១ និង២៥នាទីយប់ នៅចំណុចក្រុមហ៊ុនផ្លូវល្បឿនលឿន ស្ថិតក្នុងភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានករណី **អំពើលួចមានស្ថានទម្ងន់ទោស និងធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** មួយកើតឡើងបង្កដោយជនជាប់ចោទឈ្មោះ [redacted] **មេត្តា** ភេទប្រុស, ជនជាប់ចោទឈ្មោះ [redacted] **ចិន** ភេទប្រុស និងឈ្មោះ **ធូ** ភេទប្រុស។ នៅថ្ងៃកើតហេតុជនជាប់ចោទបានជិះម៉ូតូចំនួន ០២គ្រឿង ម៉ាកហុងដា ពណ៌ខ្មៅ ផ្លាកលេខ ពោធិ៍សាត់ 1J-0691 និងមួយគ្រឿងទៀត ម៉ាកហុងដា វេវ ពណ៌ខ្មៅ ផ្លាកលេខ ពោធិ៍សាត់ 1J-8629 ដល់ចំណុចទីតាំងខាងលើ ជនជាប់ចោទទាំង០៣នាក់ នាំគ្នាលួចកាត់ដែក បង្គោលទប់របងរបស់ក្រុមហ៊ុនល្បឿនលឿន ដែលមានដើមបណ្ដឹងឈ្មោះ [redacted] **វ៉ុក** ភេទប្រុស។ ពេលជនជាប់ចោទទាំង០៣នាក់កំពុងធ្វើសកម្មភាពកាត់ដែកនោះ គឺត្រូវបានប្រជាពលរដ្ឋនៅក្បែរទីតាំងចាប់បានជនជាប់ចោទចំនួន ០២នាក់ ប្រគល់ឱ្យសមត្ថកិច្ច។ ចំណែកឯជនជាប់ចោទឈ្មោះ **ធូ** ភេទប្រុស បាតរត់គេចខ្លួនបាត់។ បន្ទាប់ពីធ្វើការសាកសួរ ជនជាប់ចោទបានសារភាពថា ពួកខ្លួនធ្លាប់ធ្វើបានសកម្មភាពលួចកាត់ដែករបស់ក្រុមហ៊ុនល្បឿនលឿនចំនួន ០៣លើក រួចមកហើយ។ ក្រោយពីធ្វើការសាកសួររួចមន្ត្រីនគរបាលយុត្តិធម៌ក៏កសាងសំណុំរឿងរួចបញ្ជូនសំណុំរឿង និងជនជាប់ចោទ ព្រមទាំងវត្ថុតាងមកតុលាការដើម្បីចាត់ការតាមនីតិវិធី។

**-បានឃើញ:** ដីកាសន្និដ្ឋានស្ថាពរលេខ: **៣៥០ អ.យ.ង/២៣** ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

**-បានឃើញ:** ដីកាដំណោះស្រាយលេខ: **១៦០ ដ.ដ.ស/ច/២៣** ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ។

**-បានឃើញ:** ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ **៣០៣២ ត.ព.រ/២៣** ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **មេត្តា** បានឆ្លើយថា: កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២២ ខ្លួន និងបក្ខពួកមានគ្នា ០៣នាក់ មានឈ្មោះ [redacted] **ចិន** និងឈ្មោះ **ធូ** ពិតជាបានធ្វើសកម្មភាពលួចដែកបានចំនួន ២៥ដុំ ពិតប្រាកដមែន តែមិនបានលក់ផងក៏ត្រូវបានប្រជាពលរដ្ឋឃើញ ហើយក៏បានឃាត់ខ្លួនប្រគល់ឱ្យសមត្ថកិច្ច។ ពេលឃាត់ខ្លួន សមត្ថកិច្ចបានដកហូតបានម៉ូតូចំនួន ១គ្រឿង ម៉ាកសេ១២៥ សេរី២០១៩, សោរសម្រាប់ដោះខ្មៅចំនួន ២ដើម និងដែកចំនួន ២៥ដុំ។ ខ្លួន និងបក្ខពួកធ្លាប់ធ្វើសកម្មភាពលួចដោះយកដែកបង្គោលទប់បង្គោលនេះបានចំនួន ០៣ដង រួចមកហើយ។

-ជនជាប់ចោទឈ្មោះ [redacted] **ចិន** បានឆ្លើយថា: កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២២ ខ្លួន និងបក្ខពួកមានគ្នា ៣នាក់ មានឈ្មោះ [redacted] **មេត្តា** និងឈ្មោះ **ធូ** ពិតជាបាននាំគ្នាធ្វើសកម្មភាពលួចដែករបស់ក្រុមហ៊ុនផ្លូវល្បឿនលឿនបានចំនួន ៨ដុំ ស្មើនឹង ២៤គីឡូក្រាម ប្រាកដមែន។ ដោយពួកខ្លួនជិះម៉ូតូចំនួន ២គ្រឿង ដើម្បីធ្វើសកម្មភាពលួចដែកបង្គោលទប់បង្គោល បន្ទាប់ពីលួចបានហើយ ខ្លួនបានយកទៅលក់នៅកន្លែងអេតចាយមួយកន្លែងស្ថិតនៅស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ បានប្រាក់ចំនួន ៤៣.២០០ (បួនម៉ឺនបីពាន់ពីររយ) រៀល។ ចំណែកបក្ខពួកខ្លួន ២នាក់ទៀត មិនដឹងថាអ្នកណាលួចបានប៉ុន្មានដុំ និងលក់បានលុយចំនួនប៉ុន្មាននោះទេ។ លុយដែលខ្លួនលក់បាន គឺខ្លួនយកទៅផ្គត់ផ្គង់គ្រួសារ។ ពេលពួកខ្លួនធ្វើសកម្មភាពលួចម្ដងៗ



Scanned with CamScanner

ដោយប្រើប្រាស់ម៉ូតូសម្រាប់ដឹកដែក និងសោរលេខ១៩ ចំនួនពីរសម្រាប់ដោះខ្មៅ។ ពេលប្រជាពលរដ្ឋឃាត់ខ្លួនជូនសមត្ថកិច្ច គឺបានដកហូតបានម៉ូតូ ១គ្រឿង ម៉ាក WAVE សោរសម្រាប់ដោះខ្មៅលេខ១៩ ចំនួន ២ដើម និងដែកចំនួន ២៥ដុំ។ ខ្លួន និងបក្ខពួកធ្លាប់ធ្វើសកម្មភាពលួចដោះយកដែកបង្គំទប់បង្គោលនេះបានចំនួន ០៣ដង រួចមកហើយ។

-ជនរងគ្រោះឈ្មោះ [redacted] **វុក** បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា: នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២ ខ្លួនទទួលព័ត៌មានពីក្រុមហ៊ុនផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុថា មានករណីជនជាប់ចោទធ្វើសកម្មភាព លួចដែករបស់ក្រុមហ៊ុននៅតំបន់ស្ថានីយ៍ស្ទឹងហាវ K179-200 ហើយ ត្រូវបានប្រជាពលរដ្ឋប្រទះឃើញ និងចាប់ឃាត់ខ្លួនបានម្នាក់ឈ្មោះ [redacted] **មេត្តា** រួមទាំងវត្ថុតាងមួយចំនួន និងម៉ូតូ ០១គ្រឿង ជាមធ្យោបាយប្រព្រឹត្តបទល្មើស។ ក្រោយទទួលព័ត៌មានបានភ្លាមខ្លួនក៏ធ្វើដំណើរទៅកន្លែងកើតហេតុ និងបានប្រគល់ជនជាប់ចោទខាងលើ រួមទាំងវត្ថុតាងឱ្យទៅសមត្ថកិច្ចដើម្បីធ្វើការសាកសួរ និងស្វែងរកចាប់ខ្លួនបក្ខពួក។ ខ្លួនសុំបញ្ជាក់អះអាងថា កន្លងមក ក្រុមជនសង្ស័យទាំងនេះ ពួកគេតែងតែធ្វើសកម្មភាពលួចដែក និងសម្ភារៈផ្សេងៗទៀតក្នុងការដ្ឋានក្រុមហ៊ុនល្បឿនលឿនជាញឹកញាប់។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ក្រោយពីបានស្តាប់ការពិភាក្សាដេញដោលនាពេលសវនាការ តំណាងអយ្យការសូមតម្កល់បទចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] **មេត្តា** ភេទប្រុស និងឈ្មោះ [redacted] **ចិន** ភេទប្រុស ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ **១០៤០** ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២ ពីបទ **អំពើលួចមានស្ថានទម្ងន់ទោស** និងបទ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនផ្លូវល្បឿនលឿន ស្ថិតក្នុងភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ**មាត្រា ៣៥៣, មាត្រា ៣៥៧, មាត្រា ៤១០** និង**មាត្រា ៤១១** នៃក្រមព្រហ្មទណ្ឌ តំណាងអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងវិនិច្ឆ័យទោសលើជនជាប់ចោទរូបនេះ តាមច្បាប់។

-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា: ក្រោយពីបានពិនិត្យមើលអង្គហេតុ អង្គច្បាប់ ភស្តុតាង និងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដែលមានបញ្ជាក់ក្នុងសំណុំរឿងព្រហ្មទណ្ឌខាងលើ ជាពិសេសចម្លើយសារភាពរបស់ជនជាប់ចោទទាំងពីរនាក់រួចមក ខ្លួនសូមធ្វើសេចក្តីសន្និដ្ឋានដូចតទៅ ក្រោយពេលដែលកូនក្តីខ្លួនបានប្រព្រឹត្តបទល្មើសរួចមក កូនក្តីខ្លួនបានដឹងពីកំហុស និងបានឆ្លើយសារភាពនូវអំពើរបស់ខ្លួន និងមានការសោកស្តាយទៅនឹងអំពើរបស់ពួកខ្លួន។ ម្យ៉ាងទៀត មូលហេតុដែលបណ្តាលឱ្យកូនក្តីខ្លួនឈានទៅដល់ការលួចនេះ គឺដោយសារកូនក្តីខ្លួនទាំងពីរនាក់ដែលមានឈ្មោះខាងលើ មិនបានរៀនជ្រៅជ្រះ ខ្វះការពិចារណា និងមានជីវភាពក្រីក្រ។ ខ្លួនសូមសំណូមពរក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តល់នូវស្ថានសម្រាលដល់កូនក្តីខ្លួនទាំងពីរនាក់ ដោយផ្តន្ទាទោសដាក់ពន្ធនាគារតែមួយមុខ ឯទោសពិន័យជាប្រាក់ សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាកុំអនុវត្តលើកូនក្តីខ្លួន ព្រោះពួកគេមានជីវភាពខ្វះខាតខ្លាំងណាស់ ផ្អែកតាមមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ពីបទ **អំពើលួចមានស្ថានទម្ងន់ទោស** និងបទ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** តាមមាត្រា ៣៥៣, មាត្រា ៣៥៧, មាត្រា ៤១០ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។

-ជនជាប់ចោទឈ្មោះ [redacted] **មេត្តា** បាននិយាយសំដីចុងក្រោយបង្អស់ថា ខ្លួនសំណូមពរឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ព្រោះខ្លួនដឹងនូវកំហុសរបស់ខ្លួនហើយ។

-ជនជាប់ចោទឈ្មោះ [redacted] **ចិន** បាននិយាយសំដីចុងក្រោយបង្អស់ថា ខ្លួនសំណូមពរឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ព្រោះខ្លួនដឹងនូវកំហុសរបស់ខ្លួនហើយ។

**-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ**

**-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ**

**-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ**

**-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ**



Scanned with CamScanner

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តព្រះសីហនុ

## យល់ឃើញថា

១-ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ បានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **មេត្តា** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ និងឈ្មោះ [redacted] **ចិន** ភេទប្រុស អាយុ២២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ពីបទ **អំពើលួចមានស្ថានទម្ងន់ទោស** និងបទ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** ទៅជំនុំជម្រះតាមដីកាដំណោះស្រាយលេខ: **១៦០ ដ.ដ.ស/ច/២៣** ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣។

២-កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង ២១ និង២៥នាទីយប់ មានជនជាប់ចោទឈ្មោះ [redacted] **មេត្តា** ភេទប្រុស, ឈ្មោះ [redacted] **ចិន** ភេទប្រុស និងឈ្មោះ **ធូ** ភេទប្រុស បានជិះម៉ូតូចំនួន ០២គ្រឿង មាន ម៉ាកហុងដា ពណ៌ខ្មៅ ផ្លាកលេខ ពោធិ៍សាត់ 1J-0691 និងមួយគ្រឿងទៀត ម៉ាកហុងដា វ៉េវ ពណ៌ខ្មៅ ផ្លាកលេខ ពោធិ៍សាត់ 1J-8629 ដល់ចំណុចក្រុមហ៊ុនផ្លូវល្បឿនលឿន ស្ថិតក្នុងភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជនជាប់ចោទទាំងបីនាក់នាំគ្នាលួចកាត់ដែកបង្គំទប់របងរបស់ក្រុមហ៊ុនល្បឿនលឿន ដែលមានដើមបណ្តឹងឈ្មោះ [redacted] **វុំក** ភេទប្រុស។ ពេលជនជាប់ចោទទាំងបីនាក់កំពុងធ្វើសកម្មភាពកាត់ដែកនោះ ត្រូវបានប្រជាពលរដ្ឋប្រទះឃើញ និងចាប់បានជនជាប់ចោទចំនួន ០២នាក់ ប្រគល់ឱ្យសមត្ថកិច្ច។ ចំណែកឯជនជាប់ចោទឈ្មោះ **ធូ** ភេទប្រុស បានរត់គេចខ្លួនបាត់។ បន្ទាប់ពីធ្វើការសាកសួរ ជនជាប់ចោទបានសារភាពថា ពួកខ្លួនធ្លាប់ធ្វើបានសកម្មភាពលួចកាត់ដែកបង្គំផ្លូវរបស់ក្រុមហ៊ុនផ្លូវល្បឿនលឿនចំនួន ០៣លើក រួចមកហើយ។

៣-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] **មេត្តា** បានឆ្លើយថា: កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២២ ខ្លួន និងបក្ខពួកមានគ្នា ០៣នាក់ មានឈ្មោះ [redacted] **ចិន** និងឈ្មោះ **ធូ** ពិតជាបានធ្វើសកម្មភាពលួចដែកបានចំនួន ២៥ដុំ ពិតប្រាកដមែន តែមិនបានលក់ផង ក៏ត្រូវបានប្រជាពលរដ្ឋឃើញ ហើយក៏បានឃាត់ខ្លួនប្រគល់ឱ្យសមត្ថកិច្ច។ ពេលឃាត់ខ្លួន សមត្ថកិច្ចបានដកហូតបានម៉ូតូចំនួន ១គ្រឿង ម៉ាកសេ១២៥ សេរី២០១៩, សោរសម្រាប់ដោះខ្មៅចំនួន ២ដើម និងដែកចំនួន ២៥ដុំ។ ខ្លួននិងបក្ខពួកធ្លាប់ធ្វើសកម្មភាពលួចដោះយកដែកបង្គំទប់បង្គោលនេះបានចំនួន ០៣ដង រួចមកហើយ។

៤-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] **ចិន** បានឆ្លើយថា: កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២២ ខ្លួន និងបក្ខពួកមានគ្នា ៣នាក់មានឈ្មោះ [redacted] **មេត្តា** និងឈ្មោះ **ធូ** ពិតជាបាននាំគ្នាធ្វើសកម្មភាពលួចដែករបស់ក្រុមហ៊ុនផ្លូវល្បឿនលឿនបានចំនួន ៨ដុំ ស្មើនឹង ២៤គីឡូក្រាម ប្រាកដមែន។ ដោយពួកខ្លួនជិះម៉ូតូចំនួន ២គ្រឿង ដើម្បីធ្វើសកម្មភាពលួចដែកបង្គំទប់បង្គោល បន្ទាប់ពីលួចបានហើយ ខ្លួនបានយកទៅលក់នៅកន្លែងអេតចាយមួយកន្លែងស្ថិតនៅស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ បានប្រាក់ចំនួន ៤៣.២០០ (បួនម៉ឺនបីពាន់ពីររយ) រៀល។ ចំណែកបក្ខពួកខ្លួន ២នាក់ទៀត មិនដឹងថាអ្នកណាលួចបានប៉ុន្មាន និងលក់បានលុយចំនួនប៉ុន្មាននោះទេ។ លុយដែលខ្លួនលក់បាន គឺខ្លួនយកទៅផ្គត់ផ្គង់គ្រួសារ។ ពេលពួកខ្លួនធ្វើសកម្មភាពលួចម្តងៗ ដោយប្រើប្រាស់ម៉ូតូសម្រាប់ដឹកដែក និងសោរលេខ១៩ ចំនួនពីរសម្រាប់ដោះខ្មៅ។ ពេលប្រជាពលរដ្ឋឃាត់ខ្លួនជូនសមត្ថកិច្ច គឺបានដកហូតបានម៉ូតូ ១គ្រឿង ម៉ាក WAVE សោរសម្រាប់ដោះខ្មៅលេខ១៩ ចំនួន ២ដើម និងដែកចំនួន ២៥ដុំ។ ខ្លួន និងបក្ខពួកធ្លាប់ធ្វើសកម្មភាពលួចដោះយកដែកបង្គំទប់បង្គោលនេះបានចំនួន ០៣ដង រួចមកហើយ។

៥-អំណានកំណត់ហេតុចម្លើយជនរងគ្រោះឈ្មោះ [redacted] **វុំក** បានឆ្លើយថា: នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២ ខ្លួនទទួលព័ត៌មានពីក្រុមហ៊ុនផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុថា មានករណីជនជាប់ចោទធ្វើសកម្មភាព លួចដែករបស់



Scanned with CamScanner

ក្រុមហ៊ុននៅតំបន់ស្ពានីយ៍ស្ទឹងហាវ K179-200 ហើយ ត្រូវបានប្រជាពលរដ្ឋប្រទះឃើញ និងចាប់ឃាត់ខ្លួនបានម្នាក់ ឈ្មោះ[redacted] **មេត្តា** រួមទាំងវត្ថុតាងមួយចំនួន និងម៉ូតូ ០១គ្រឿង ជាមធ្យោបាយប្រព្រឹត្តបទល្មើស។ ក្រោយទទួលព័ត៌មានបាន ភ្លាមខ្លួនក៏ធ្វើដំណើរទៅកន្លែងកើតហេតុ និងបានប្រគល់ជនជាប់ចោទខាងលើ រួមទាំងវត្ថុតាងឱ្យទៅសមត្ថកិច្ចដើម្បីធ្វើការ សាកសួរ និងស្វែងរកចាប់ខ្លួនបក្ខពួក។ ខ្លួនសុំបញ្ជាក់អះអាងថា កន្លងមក ក្រុមជនសង្ស័យទាំងនេះ ពួកគេតែងតែធ្វើ សកម្មភាពលួចដែក និងសម្ភារៈផ្សេងៗទៀតក្នុងការដ្ឋានក្រុមហ៊ុនល្បឿនលឿនជាញឹកញាប់។

៦-តាមរបាយការណ៍លេខ: **២៥៧ រ.ប.ក/២២** ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ការិយាល័យនគរបាល ព្រហ្មទណ្ឌកម្រិតធ្ងន់ នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានសន្និដ្ឋានថា: ឈ្មោះ [redacted] **មេត្តា** និងឈ្មោះ [redacted] **ចិន** គឺ ជាសហចារីក្នុងករណី **អំពើលួចមានស្ថានទម្ងន់ទោស** កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២ នៅចំណុចក្រុមហ៊ុនផ្លូវ ល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ ពិតប្រាកដមែន។

៧-ចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] **មេត្តា** និងឈ្មោះ [redacted] **ចិន** និងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **វុក** មានភាពស៊ីចង្វាក់គ្នាជាមួយរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ អាចបញ្ជាក់យ៉ាងច្បាស់ថា ជនជាប់ចោទឈ្មោះ [redacted] **មេត្តា** និងឈ្មោះ[redacted] **ចិន** ពិតជាបានយកខ្មៅលួចដោះ និងកាត់យកដែកបង្គំរបស់ផ្លូវល្បឿនលឿន ក្នុងចេតនាបំផ្លិច បំផ្លាញ ធ្វើឱ្យខូចខាត និងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួននូវទ្រព្យសម្បត្តិរបស់អ្នកដទៃ ពិតប្រាកដមែន។

៨-អំពើរបស់ជនជាប់ចោទឈ្មោះ[redacted] **មេត្តា** និងឈ្មោះ[redacted]**ចិន** មានចេតនាទុច្ចរិតលួចដោះ និងកាត់យកដែកបង្គំ ផ្លូវល្បឿនលឿន ក្នុងចេតនាបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាត និងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួននូវទ្រព្យសម្បត្តិរបស់ជនរងគ្រោះ មកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន គឺជាបទល្មើសព្រហ្មទណ្ឌដែលច្បាប់បញ្ញត្តិថាជា **អំពើលួចមានស្ថានទម្ងន់ទោស** និង**ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស**។

៩-ជនជាប់ចោទឈ្មោះ[redacted] **មេត្តា** និងជនជាប់ចោទឈ្មោះ [redacted] **ចិន** ក្នុងពេលប្រព្រឹត្ត និងក្រោយពេលប្រព្រឹត្ត ជននេះមានសមត្ថភាពលទ្ធភាពគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន។

១០-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាប់លើឈ្មោះ[redacted] **មេត្តា** ភេទប្រុស អាយុ២៣ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] **ចិន** ភេទប្រុស អាយុ២២ឆ្នាំ ពីបទ **អំពើលួចមានស្ថានទម្ងន់ទោស** និងបទ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** ប្តឹងសុំឱ្យតុលាការសម្រេចតាមនីតិវិធីច្បាប់ គប្បីតុលាការលើកយកការសន្និដ្ឋាន របស់តំណាងអយ្យការមកពិចារណាក្នុងការសម្រេចសេចក្តី។

១១-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ អាចឱ្យតុលាការលើកយកមកពិចារណាបាន។

១២-នៅដំណាក់កាលស៊ើបសួរ ក៏ដូចជានាពេលសវនាការជនរងគ្រោះឈ្មោះ [redacted] **វុក** ពុំបានតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីក្នុងការទាមទារសំណងទេ ដូច្នេះគប្បីតុលាការមិនពិចារណាអំពីសំណងរដ្ឋប្បវេណីនោះទេ ទុកសិទ្ធិឱ្យ ជនរងគ្រោះប្តឹងទាមទារនៅពេលក្រោយ។

១៣-ជនជាប់ចោទមានមុខរបរមិនច្បាស់លាស់ និងមានជីវភាពខ្វះខាត គប្បីតុលាការសម្រេចផ្តន្ទាទោសលើ ជនជាប់ចោទតែមួយមុខ រីឯទោសពិន័យជាប្រាក់ ពុំគប្បីអនុវត្តលើជនជាប់ចោទរូបនេះឡើយ ស្របតាម**មាត្រា ៩៧** នៃ ក្រមព្រហ្មទណ្ឌ។

១៤-វត្ថុចាប់យកមាន៖

-ម៉ូតូចំនួន ០២គ្រឿង (ម៉ាក ហុងដា C-125 ពណ៌ខ្មៅ ផលិតឆ្នាំ២០១៩ ពាក់ស្លាកលេខ ពោធិ៍សាត់ 1J-0691 និង ម៉ាក ហុងដា WAVE ពណ៌ខ្មៅ ពាក់ស្លាកលេខ ពោធិ៍សាត់ 1J-8629) និងដាវ ០១ដើម (ប្រវែង ៤៥ ស.ម) ជាមធ្យោបាយ ប្រព្រឹត្តបទល្មើស គប្បីរឹបអូសស្របតាម**មាត្រា ៦២** នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

-ម៉ូតូចំនួន ០២គ្រឿង (ម៉ាក ហុងដា C-125 ពណ៌ខ្មៅ ផលិតឆ្នាំ២០១៩ ពាក់ស្លាកលេខ ពោធិ៍សាត់ 1J-0691 និង ម៉ាក ហុងដា WAVE ពណ៌ខ្មៅ ពាក់ស្លាកលេខ ពោធិ៍សាត់ 1J-8629) និងដាវ ០១ដើម (ប្រវែង ៤៥ ស.ម) ជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីរឹបអូសស្របតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

១៥-មានភស្តុតាង និងមានពិរុទ្ធភាពដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] មេគ្គា ភេទប្រុស អាយុ២៣ឆ្នាំ និងឈ្មោះ [redacted] ចិន ភេទប្រុស អាយុ២២ឆ្នាំ ពីបទ **អំពើលួចមានស្ថានទម្ងន់ទោស** និងបទ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនផ្លូវល្បឿនលឿន ស្ថិតក្នុងភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៧, មាត្រា ៤១០ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

**១-ផ្តន្ទាទោសជនជាប់ចោទ៖**

១.១-ឈ្មោះ[redacted] មេគ្គា ភេទប្រុស កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ។

១.២-ឈ្មោះ [redacted] ចិន ភេទប្រុស កើតឆ្នាំ២០០០ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ។

ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** និងបទ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនផ្លូវល្បឿនលឿន ស្ថិតនៅភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៧, មាត្រា ៤១០ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។

**២-រឹបអូសវត្ថុចាប់យក** មានដូចជា៖

-ម៉ូតូចំនួន ០២គ្រឿង (ម៉ាក ហុងដា C-125 ពណ៌ខ្មៅ ផលិតឆ្នាំ២០១៩ ពាក់ស្លាកលេខ ពោធិ៍សាត់ 1J-0691 និង ម៉ាក ហុងដា WAVE ពណ៌ខ្មៅ ពាក់ស្លាកលេខ ពោធិ៍សាត់ 1J-8629) និងដាវ ០១ដើម (ប្រវែង ៤៥ ស.ម) ស្របតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] មេគ្គា និងឈ្មោះ [redacted] ចិន មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា [redacted] | | | |

.................................................................................................................................

"បានចំលងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៥រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ខេត្តព្រះសីហនុ, ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner